# ការសម្ភាសរបស់លោកយាយ ហាក់ យិន

កៈ អ្នកសម្ភាស ញ៉ែម លាភី ខៈ អ្នកត្រូវគេសម្ភាស ហាក់ យិន

គៈ ប៉ិច(កូនស្រីលោកយាយ ហាក់ យិន)

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះហាក់ យិន</u>

លោកយាយ ហាក់ យិនគាត់ជាអ្នកខេត្តតាកែវ ហើយគាត់បានឆ្លងកាត់សង្គ្រាមលំបាកគេឱ្យគាត់រែកដីហើយស្វាមីរបស់លោកយាយបានស្លាប់កាលពេលនៅក្នុងសង្គ្រាមហ្នឹងដែរ ព្រោះដោយសារអត់មានអ្វីហូបហើយដាច់ពោះស្លាប់ហើយលោកយាយត្រូវមើលថែកូន៩នាក់តែម្នាក់ឯង។នៅក្នុងនេះគាត់មិនសូវបាននិយាយច្រើនប៉ុន្មានទេព្រោះគាត់មានអាយុច្រើនហើយគាត់ងងឹតហើយត្រចៀកស្តាប់ពុំសូវបានទៀត។ មុនជំនាន់សង្គ្រាមគាត់ជាកូនអ្នកដែលមានទ្រព្យសម្បត្តិធូរធារហើយគាត់មិនដែលពិបាកទេ ហើយគាត់មកពិបាកនៅពេលជំនាន់សង្គ្រាមហើយពេលស្វាមីគាត់ស្លាប់។

កៈ ខ្ញុំសូមជម្រាបសួរលោកយាយថ្ងៃនេះខ្ញុំឈ្មោះញ៉ែម លាភី សុំសម្ភាសអ្នកមីងនៅក្នុងថ្ងៃនេះ។នៅក្នុងថ្ងៃអង្គារ៍ទី១៥ ខែឧសភា ឆ្នាំ២០១៨។ ហើយការសម្ភាសនេះត្រូវបានធ្វើឡើងនៅក្នុងភូមិថ្មល់ទក្សិណ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។ហើយលោកយាយមានឈ្មោះអីគេដែរលោកយាយ?យាយមានឈ្មោះពេញឈ្មោះអ្វីដែរ?

ខៈ ហាំ?

គៈ ម៉ែឯងឈ្មោះអី?

កៈ ឈ្មោះអី?

ខ៖ ឈ្មោះយិន។

ក៖ ឈ្មោះយិន ត្រកូលអីគេ?

គ៖ ហាក់ យិនហេ?

ខ៖ ហាក់ យិន។

ក៖ ហាក់ យិន ហើយលោកយាយអាយុប៉ុន្មានហើយសព្វថ្ងៃ?

ខ៖ ខ្ញុំដូចអាយុគ្រែលដែលហើយ៨០ផ្លាយហើយ។

គ៖ ៨០ប៉ុន្មានប្រាប់ទៅ ៨២។

ក៖ លោកយាយមើលទៅដូចជាកូនក្មេងទៅវិញហើយណាស់។

គ៖ ដូចកូនក្មេង ម៉ែឯងអាយុប៉ុន្មាន?

ក៖ យាយអាយុប៉ុន្មានហើយ?

ខ៖ អាយុ៨០ហើយកូន។

ក៖ ចាសហើយយាយកើតនៅឯណាដែលយាយ?

ខ៖ ហេ...កើតនៅឆ្នាំណាទេ ភ្លេចមើលឆ្នាំ។

គ៖ កើតនៅឯណា?ម៉ែឯងឃើញកើតនៅក្នុងភូមិថ្មល់ទក្សិណហ្នឹងហេ?

ខ៖ នៅភូមិចាស់ឯណោះ យើងពីដើមនៅភូមិចាស់។កើតនៅភូមិហ្នឹងដែរស្រុកនៅជាមួយតែគ្នាហ្នឹង។

ក៖ ចាសនៅខេត្តតាកែវហ្នឹងដែរ?

ខ៖ ខេត្តតាកែវ ឃុំក្រាំង ធ្នង់ ហ្នឹង។

ក៖
ចាសលោកយាយនៅពីក្មេងលោកយាយមានអ្នកណាគេហៅលោកយាយក្រៅពីឈ្មោះមួយហ្នឹងអត់ទេលោកយាយ?

ខ៖ អត់ទេអត់មានទេ។

ក៖ អត់មានងារអីផ្សេងទេ?

ខ៖ អត់មានឈ្មោះអីទេ។

ក៖ ចាសលោកយាយឆ្នាំខ្មែរលោកយាយឆ្នាំអីគេដែរ?

ខ៖ ឆ្នាំអីកូន?

ក៖ ឆ្នាំខ្មែរណាស់ លោកយាយកើតឆ្នាំខ្មែរដូចថាឆ្នាំថោះរោង ម្សាញ់ មមី មមែអីអញ្ចឹងណាស់?

គ៖ ម៉ែឯងឆ្នាំអីគេ?

ខ៖ កើតឆ្នាំជូត។

ក៖ ឆ្នាំជូតហើយអឺ...លោកយាយរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ហាំ?

ក៖ ធ្លាប់រៀនត្រឹមថ្នាក់ទីប៉ុន្មាន?

គ៖ ធ្លាប់រៀនម៉ែឯងមានធ្លាប់រៀនទេ?

ខ៖ អត់ទេ អត់បានរៀនទេចៅ។

ក៖ អត់ដែលបានចូលសាលារៀនសោះ?

ខ៖ អត់។

ក៖ ចុះលោកយាយអត់ដែលចេះភាសាអក្សរខ្មែរ ចេះអានចេះមើលអីទេណោះ?

ខ៖ អត់។

កៈ អត់ដែលចេះ។

ខៈ អត់ដែលចេះ។

កៈ អក្សរខ្មែរក៏អត់ដែលចេះអី។

ខៈ អត់ចេះអត់បានរៀនតែម្តង។

កៈ ចាសកាលលោកយាយកើតនៅក្នុងសង្គមអីគេលោកយាយ?

ខៈ ហាស?

កៈ កាលលោកយាយកើតនៅក្នុងសង្គមអីគេដែរ?

គៈ សង្គម លន់ នល់ ឬក៏អី?សង្គមសម្តេចតាគេហៅសង្គមអី?

ខៈ អត់ដឹងទេ។

គៈ សង្គមសម្តេចតាហ្នឹងគេហៅថាសង្គមអី?

ខៈ សង្គមសម្តេចតាអាម៉េច?

គៈ ចុះក្រែងម៉ែឯងកើតរស់នៅក្នុងសង្គមសម្តេចតាគ្រប់គ្រង អាហ្នឹងរាជ្យលន់ នល់ហេ?ឬក៏អី?

ខៈ ក្រាំងធ្នង់។

គៈ ហ៊ឺ...!

កៈ អត់អីទេព្រោះអីរៀងគាត់ចាស់អាយុច្រើនពេកគាត់វង្វេង។

ខៈ ឃុំគេហៅអញ្ចេះហេ?

កៈ ចាស!

ខៈ ឃុំហ្នឹងមានតែឃុំក្រាំង ធ្នង់ ឃុំក្រាំង ធ្នង់ ស្រុកបាទី ខេត្តតាកែវ។

កៈ ចុះលោកយាយម្តាយរបស់លោកយាយឈ្មោះអីគេទៅ?

ខ៖ ម្ដាយឈ្មោះយិន គាត់ស្លាប់បាត់ហើយ យូរហើយ។

ក៖ ចាសយាយចាំបានទេថាគាត់អាយុប៉ុន្មានពេលគាត់ស្លាប់?

ខ៖ គាត់ស្លាប់មិនដឹងឆ្នាំអាយុប៉ុន្មានទេ ភ្លេចភ្លាំងអស់ហើយយូរហើយអូន។

ក៖ ចាស!

ខ៖ គាត់ស្លាប់តាំងពីពេល នៅភូមិចាស់ភូមិអីណោះ។

ក៖ ចាសប្រហែលជាអាយុប៉ុន្មានឆ្នាំហើយយាយមកដល់ឥឡូវយាយ?

ខ៖ បើតាមគិតយូរហើយឆ្នាំ គាត់ស្លាប់យូរហើយ។

ក៖ ចុះឪពុករបស់យាយគាត់ឈ្មោះអីគេដែរ?

ខ៖ ដូចថាវាអត់គិតគូរអី។

គ៖ ចុះឪពុកម៉ែឯងឈ្មោះអីគេ មីអូនសួរណាស់។

ក៖ ឪពុករបស់យាយគាត់ឈ្មោះអីគេដែរ?

ខ៖ ឪពុកហេ?

ក៖ ចាសឪពុកឈ្មោះអី?

ខ៖ ឪពុកគាត់ឈ្មោះងៀម។

ក៖ ងៀម?ត្រកូលគាត់អីគេយាយ?

ខ៖ គាត់ឈ្មោះងៀមខ្ញុំឈ្មោះយិនហ្នឹង ងៀម យិន។

ក៖ ចាសគាត់កាលពេលស្លាប់ដោយសារអីគេទៅយាយ?

ខ៖ ហាំ?

ក៖ តាគាត់ស្លាប់ដោយសារអីគេដែរ?

គ៖ គាត់ឈឺ។

ខ៖ គិតទៅមែនអត់គិតអាយុ គាត់ស្លាប់នៅឆ្នាំណាក្នុងឆ្នាំណាអីអត់ដឹងអត់គិតចេះតែហីៗទៅ។

ក៖ ចុះកាលគាត់ស្លាប់គាត់ឈឺមែនទេយាយ?

ខ៖ គាត់ឈឺគាត់។

ក៖ ចុះលោកយាយមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ មិនទៅជរាអីប៉ុន្មានទេ គាត់ចាស់គាត់ឈឺល្មម មើលមិនជាណាស់។

ក៖ ចាសតើយាយមានចាំបងប្អូនរបស់យាយឈ្មោះអីគេខ្លះអត់?

ខ៖ បងប្អូនហេ?

ក៖ ចាស!

ខ៖ បងប្អូន?

គ៖ ឈ្មោះធំប៊ុត។

ខ៖ ២យាយយ៉ុម ៣មីថុន។

គ៖ ៤ពូស្រេង។

ខ៖ ៣យាយថុន ៤ខ្ញុំហ្នឹង។

គ៖ ប្រាំពូស្រេង។

ខ៖ អើរ…!

ក៖ គាត់ស្លាប់អស់ហើយតើយាយហេ?

ខ៖ ស្លាប់អស់ហើយមីអូនអើយ។

កៈ គាត់ស្លាប់ដោយសារអីគេយាយ?

ខៈ ស្លាប់អស់រលីង។

កៈ ចាសតែគាត់ស្លាប់ដោយសារអីគេទៅ?

ខៈ ស្លាប់ឈឺហ្នឹង មិនដឹងជាឈឺអីគេទេ ឈឺធម្មតា។

កៈ ចាសចុះកាលពេលជំនាន់ប៉ុលពតលោកយាយចាំថាលោកយាយជួបបញ្ហាអីគេខ្លះអត់?ដូចថាធ្លាប់ឆ្លងកាត់ការលំបាកអីគេខ្លះនៅក្នុងជំនាន់ប៉ុល ពតយាយ?

ខៈ កាលពេលជំនាន់អាពតហោ?

កៈ ចាស!

ខៈ ជំនាន់អាពតពិបាក។

គៈ ពិបាកម៉េចម៉ែឯងចេះតែនិយាយទៅ។

កៈ គេធ្លាប់ធ្វើបាបម៉េចខ្លះទៅយាយ?

ខៈ គេអត់មានធ្វើបាបអីគេទេតែគ្រាន់តែថា...។

គៈ គេបង្អត់អត់អីហូប។

ខៈ គេបង្អត់អត់អីហូប អត់មានអីហូប។

គៈ ធ្វើការអត់មានស្គាល់យប់អត់មានស្គាល់ថ្ងៃ។

ខៈ ធ្វើការអត់មានដឹងយប់ដឹងថ្ងៃទេ តែធ្វើឱ្យគេទៅណាស់។

កៈ ចាស!

គ៖ ហើយហូបមិនដែលឆ្អែតប៉ុណ្ណឹងហើយអត់ធ្វើបាបទៀត អញ្ចឹងចង់នៅជំនាន់អាពតម៉ែឯងនៅសង្គមអាពតទៀតទៅ ស្រួលគេអត់ធ្វើបាបផង គេឱ្យវែកដីកូនទើបបានមួយខែកន្លះគេឱ្យទៅលីដីនៅអត់ធ្វើបាបទៀត។

ខ៖ វែកតែដីហ្នឹងណាស់។

ក៖ យាយកាលពេលនៅក្មេងយាយធ្វើការអីគេដែរ?

ខ៖ គេកំពុងថាឱ្យតែវែកតែដីកូន។

ក៖ វែកតែដី?

ខ៖ អាពតហ្នឹងឯង។

ក៖ ចាសនៅជំនាន់អាពតហ្នឹង ចុះនៅមុនជំនាន់ប៉ុល ពតហ្នឹងយាយធ្វើការអីគេទៅ?

ខ៖ ជំនាន់ប៉ុល ពតហ្នឹង។

ក៖ ចាសមុនហ្នឹងទៀតណាស់ មុនជំនាន់ប៉ុល ពតទៀតណាស់?

ខ៖ ធ្វើការធម្មតា យើងរកស៊ីធ្វើស្រែធ្វើអីអញ្ចឹងទៅណាស់។

ក៖ ចាសយាយអត់មានធ្វើការងារអីផ្សេងទៀតទេហេ?

ខ៖ ដូចថាមុនអាពត ធ្លាប់ធ្វើការគេយកទៅ វែកដីវែកអីអញ្ចឹងទៅ។

ក៖
កាលពេលនៅក្មេងឪពុកម្ដាយរបស់យាយធ្លាប់និយាយអំពីប្រវត្តិរឿងរ៉ាវរបស់គាត់ប្រាប់យាយអត់?

ខ៖ អត់។

ក៖ អត់ដែរទេ?

ខ៖ ចាស!

កៈ គាត់អត់ដែលប្រាប់ថា ហ្វ៎...នៅក្មេងៗគាត់ធ្លាប់ធ្វើការងារអីរៀននៅណាគាត់ដែលប្រាប់អត់យាយ?

ខៈ គាត់អត់ដែលប្រាប់ទេ។

កៈ ចាសចុះកាលពីពេលយាយនៅក្មេង?

ខៈ គ្រាន់តែដឹងថាពេលនៅក្មេងៗមកគាត់ធ្វើត្នោតគាត់ធ្វើស្ករណាស់។

កៈ ហ្វ៎...គាត់ចេះធ្វើត្នោតធ្វើស្ករ?

ខៈ ធ្វើស្ករធ្វើត្នោត។

កៈ តាគាត់អ្នកធ្វើយាយណោះ?

ខៈ តាគាត់អ្នកធ្វើត្នោតដែរ។

កៈ គាត់ឡើងខ្លួនឯងមែនទេយាយ?

ខៈ គាត់ឡើង ហើយកាលប្រវត្តិគាត់រែកអត់រួច ខ្ញុំទៅជួយរែកគាត់មកផ្ទះមក។

កៈ ចាស!

ខៈ រែកទឹកត្នោតណាស់។

កៈ ចាស!

ខៈ ពេញៗបំពង់ធ្វើហ្នឹង។

កៈ គាត់ធ្វើនៅណាវិញយាយ?

ខៈ គាត់នៅចម្ការគាត់នៅទៅ ទៅព្រៃលើទៅអញ្ចឹងទៅណាស់។

កៈ ចុះម្ដាយរបស់យាយគាត់ជួយធ្វើគាត់ឬក៏មានការងារធ្វើអីគេផ្សេង?គាត់ជួយតាអត់យាយ?

ខៈ យាយហោ?

ក៖ ចាសគាត់មានជួយតាអត់?

ខ៖ យាយគាត់បានកូនជួយហើយ គាត់មិនបានសូវជួយទេ ជួយតែរកអុសទៅរកអីទៅហ្នឹង ដែរ។

ក៖ ចុះយាយជាកូនទីប៉ុន្មានដែរ?

ខ៖ រកអុសដុតភ្លើងស្ករហ្នឹងណាស់។

ក៖ យាយជាកូនទីប៉ុន្មានដែរ?

ខ៖ ខ្ញុំហេ?

ក៖ ចាស!

គ៖ ម៉ែឯងកូនទីប៉ុន្មាន?

ខ៖ ខ្ញុំកូនទីប៉ុន្មានហ្អែងសួរ?

គ៖ ម៉ែឯងហ្នឹងកូនទីប៉ុន្មាន?

ខ៖ ណែ...រាប់មើលសិន។

ក៖ ចាសរាប់មើលសិនទៅ។

ខ៖ យាយថុន៣ យាយឃុម៤ អញទី៤ហើយកូន។

ក៖ ចាសទី៤ យាយមានដែលធ្លាប់ទៅលេងខេត្តណាផ្សេងអត់?

ខ៖ ហាំ??

ក៖ ដែលទៅលេងខេត្តផ្សេងអត់ ដូចថាដែលធ្លាប់ទៅលេងខេត្តណាផ្សេងហាំ...ក្រៅពីខេត្តតាកែវហ្នឹងណាស់?

គ៖ មានដែលដើរលេងកំសាន្តឯណាឯណី ចុះម៉ែឯងថាជិះដំរីជិះអីទៅភ្នំតាម៉ៅនោះ?

ខ៖ ហ្ហ៎...ទៅលេងហោ?

ក៖ ចាស!

ខ៖ ដែលទៅ ដែលទៅលេងភ្នំជីសូរ។

គ៖ ជិះដំរី?

ខ៖ ជិះដំរី ជួលដំរីគេជិះទៅ សប្បាយណាស់។

ក៖ ចាស!

ខ៖ ជិះដំរី អើរ...ទៅដំរី១០ដំរីអីអញ្ចឹងទៅណាស់មីនាង ទៅលេងភ្នំជីសូរហ្នឹង។

ក៖ ចុះដែលទៅលេងកំពង់សោមដែរឬក៏អត់លោកយាយ?

ខ៖ ចាំ?

ក៖ កំពង់សោមទៅសមុទ្រណាស់?

ខ៖ អើរ...ទៅសមុទ្រ ទៅសមុទ្រខ្ញុំមិនដែលទៅផង។

ខ៖ អត់។

ក៖ អត់ដែលទៅដែរ?

ខ៖ ចាស!

ក៖ យាយអត់សូវបានស្គាល់កន្លែងច្រើនដែរ?

ខ៖ខ្ញុំ អត់សូវបានស្គាល់ទេចៅ។

ក៖ ចាស!

ខ៖ អត់សូវបានស្គាល់កន្លែងច្រើនអត់ទេ អត់ស្គាល់ទេ ស្គាល់តែពេលរាជ្យអាពតហ្នឹងកាលពេលវាយកទៅកុំអីអត់ទៅស្គាល់សោះហ្នឹង។

គ៖ ស្គាល់គាត់ស្គាល់ ស្គាល់បាត់ដំបងស្គាល់អីពេលសង្គមអាពត។

ក៖ ចាស!

គ៖ ដល់ពេលចូលមកដល់សម័យគេដើរលេងឥឡូវនេះគាត់អត់ស្គាល់ទេ អត់មានស្គាល់ទេ។

ក៖ យាយកាលពេលជំនាន់ប៉ុល ពតយាយរស់នៅឯណាទៅ?

ខ៖ រាជ្យសង្គមអាពតហ្នឹងហី?

ក៖ ចាសយាយនៅឯណា?

ខ៖ នៅស្រុកហ្នឹងដែរហ្នឹង។

គ៖ នៅព្រះនេត្រព្រះហី?

ខ៖ ហេ...ភ្លេចអស់ហើយហាំ...។

គ៖ ជំនាន់អាពតនៅព្រះនេត្រព្រះ នៅស្រុកគេនៅព្រះនេត្រព្រះហេ...ហើយម៉េចមកនៅស្រុកហ្នឹងដែរអាម៉េច...ម៉េចត្រូវ?

ខ៖ ហ្ហ៎...ទៅព្រះនេត្រព្រះហើយ។

ក៖ យាយរៀងភ្លេចអស់ហើយអាយុច្រើនពេក។

គ៖ ភ្លេចអស់ហើយហ្នឹងអូន។

ខ៖ អញ្ចឹងបានថាអញភ្លេចភ្លាំងអស់ហើយហ្នឹងណាស់។

ក៖ ចាសយាយធ្លាប់និយាយប្រាប់រឿងរ៉ាវប្រាប់កូនៗដែរតើហេយាយ?

គ៖ ធ្លាប់និយាយដែរតើ។

ក៖ ចាសធ្លាប់និយាយដែរ ហើយអើរ...លោកយាយមានកូនប៉ុន្មាននាក់ដែរ?

ខ៖ កូន កូនអើរ...?

គ៖ កូនម៉ែឯងទាំងអស់ប៉ុន្មានទាំងអស់?

ខ៖ កំពុងរាប់ ចង់ភ្លេចភ្លាំងកូន កូនហ្នឹងក៏ស្លាប់។

ក៖ កូននៅសល់ប៉ុន្មាននាក់យាយ?

ខ៖ កំពុងតែរាប់មើលឈ្មោះ...ឈ្មោះអើរ...អាធា១។

ក៖ ចាសឈ្មោះអីគេលោកយាយ?

ខ៖ អាធា១ ប្រុស។

ក៖ ចុះមួយទៀត?

ខ៖ ហើយស្រីមួយនោះឈ្មោះនាងពឿន នោះឈ្មោះមីទី២ បូនធុច។

ក៖ ទី៤អ្នកមីងអីគេយាយ?

ខ៖ ទី៤នាងផាត់។

ក៖ ចាសទី៥?ចុះមីងនៅជិតហ្នឹងគាត់ឈ្មោះអីគេយាយ?

ខ៖ ហាំ...?

ក៖ មីងគាត់នៅជិតហ្នឹងគាត់ឈ្មោះអីគេដែរ?

ខ៖ នេះហេ?

ក៖ ចាស!

ខ៖ ឈ្មោះប៉ិច។

ក៖ ពេជ្រ?

គ៖ ប៉ិច។

ខ៖ អើរ...ភ្លេចនាងប៉ិចមួយ ឥឡូវនឹកឃើញហើយ។

កៈ ចាសលោកយាយងងឹតតាំងពីពេលណាមក?ប៉ុន្មានឆ្នាំហើយយាយ?

ខៈ ហ៊ឺ...យូរហើយចៅ។

កៈ យាយដោយសារជម្ងឺឬក៏ដោយសារយាយចាស់មើលទៅលែងឃើញអញ្ចឹង?

ខៈ នាងអើយសុទ្ធតែចាស់ហើយបានងងឹត។

កៈ ចាស!

ខៈ ងងឹតចូលជំនាន់ចូលអាពតហ្នឹង។

កៈ តាំងពីជំនាន់ប៉ុល ពតមកងងឹតតែម្តង?

ខៈ ហ្នឹងហើយ។

កៈ ហ្វ៎...យាយកាលពេលជំនាន់ប៉ុល ពតយាយអាយុប៉ុន្មានដែរ?

គៈ ម៉ែប្រហែលជាអាយុ៩០។

កៈ អាយុ៩០ជាង ចុមអញ្ចឹងគាត់ងងឹតយូរដែរហើយជំនាន់តាំងពីគាត់នៅ៩០ជាង?

គៈ អត់ទេគាត់នៅជំនាន់អាពតគាត់មេម៉ាយប្តីគាត់អាយុ៩០តែគាត់ចូលងងឹតនេះខ្ទង់៦០។

កៈ ហ្វ៎...!

ខៈ ជំនាន់ប៉ុល ពតខ្ញុំខ្ទង់៥០ ខ្ទង់៣០អីណោះហេ...។

គៈ ម៉ែឯងងងឹតហ្នឹងខ្ទង់៦០។

កៈ ពេលងងឹតហ្នឹងខ្ទង់៦០ហើយ។

គៈ ឥឡូវ៧០ ៨០ជាងហើយងងឹត២០ឆ្នាំជាងណាស់។

កៈ ចុះប្តីរបស់យាយឈ្មោះអីគេយាយ?

គៈ ឈ្មោះតាមាស។

ខ៖ គាត់ឈ្មោះមាស។

ក៖ ចាសសព្វថ្ងៃគាត់នៅរស់ដែរឬក៏អត់យាយ?

ខ៖ គាត់នៅភូមិជាមួយគ្នាហ្នឹង។

ក៖ ចាសតែគាត់ស្លាប់ឬក៏រស់?

ខ៖ ប្រវត្តិគាត់ពេលនៅ...។

កូន៖ គាត់ស្លាប់ឬក៏រស់ម៉ែគ្រាន់តែឆ្លើយទៅ។

ខ៖ គាត់ស្លាប់នៅស្រុកគេនោះអីហើយ។

ក៖ គាត់ស្លាប់ដោយសារប៉ុល ពតហ្នឹងមែនទេលោកយាយ?

ខ៖ ហ្នឹងហើយ។

គ៖ ស្លាប់ដោយសារអត់បាយហូប។

ក៖ ដោយសារអត់អីហូបបានគាត់ស្លាប់។

ខ៖ ស្លាប់នៅស្រុកគេនោះ ស្លាប់នៅភូមិព្រះនេត្រព្រះ។

គ៖ គាត់អត់ឈឺទេ គាត់ស្លាប់ដាច់បាយ វាអត់មានបាយហូប។

ខ៖ នៅស្រុកមោងហ្នូ...។

ក៖ ស្រុកមោង ខេត្តបាត់ដំបងហ្នឹងមីងហី?

គ៖ ហ្នឹង។

ខ៖ ហ្នឹងហើយខេត្តបាត់ដំបង។

ក៖ ចាស!

ខ៖ គាត់ដាច់បាយ ដាច់ពោះបាយ។

គ៖ អត់មានបាយហូប មិនមែនដាច់ពោះបាយអត់ហូបកើតទេណាស់ គឺអត់មានអង្ករបាយ។

ខ៖ អត់អង្ករ។

ក៖ អត់អង្ករអត់ម្ហូបបានគាត់ស្លាប់។

ខ៖ ហ្នឹងហើយវាអត់ ហើយហេវទៅៗ។

គ៖ ហូបតែស្លឹកឈើចង់មួយខែ ពីរខែម៉្លោះហើយអត់អីហូបណាស់។

ក៖ ចាសគាត់អាយុប៉ុន្មានកាលស្លាប់មានចាំទេលោកយាយ?

ខ៖ គាត់ស្លាប់ អាយុបែបខ្ទង់ ៣០ ៥០អីហ្នឹង។

ក៖ ៣០ ៥០អី?

ខ៖ ខ្ទង់៥០ហ្នឹង។

ក៖ ពេលហ្នឹងលោកយាយមានកូន៩នាក់ហើយហើយ?

ខ៖ ចាស!

ក៖ ហ្ហ៎...ត្រូវមើលកូន ត្រូវរ៉ាប់រងកូនទាំង៩នាក់ដោយខ្លួនឯង។

ខ៖ ហ្នឹង។

ក៖ ពិបាកចិត្តប្តីស្លាប់ហើយកូនច្រើនទៀត។

ខ៖ វាពិបាក។

ក៖ ហើយជំនាន់ប៉ុល ពតអញ្ចឹងទៀត អូយ...យាយពិបាកខ្លាំងមែនទែនតែម្តងណាស់ ហើយកូនមានអីហូបទៅអញ្ចឹងត្រូវអត់ទាំងអស់គ្នា អូយ...យ៉ាប់ណាស់ លោកយាយមានមិត្តភក្តិជិតស្និតដែលធ្លាប់លេងជាមួយគ្នាអីអត់លោកយាយ?

ខ៖ ហា៎?

ក៖ មានមិត្តភក្តិជិតស្និតដែរអត់?

ខ៖ អត់ទេ។

ក៖ អត់ទេ?ហើយលោកយាយកាលពេលនៅក្មេងលោកយាយចូលចិត្តលេងអីគេដែរ?

ខ៖ នៅក្មេងចូលចិត្តលេងល្បែង អត់មានចេះលេងល្បែងអីគេទេ។

ក៖ ដូចថាលេងឈូងលេងអីអញ្ចឹងៗ?

ខ៖ គ្រាន់តែលេងឈូងលេងអីធម្មតា។

ក៖ ចាស!

ខ៖ លេងរាំវង់រាំអីនឹងគេទៅណាថៅ។

ក៖ កាលពេលជំនាន់មុនសប្បាយអត់យាយ? កាលជំនាន់យាយនៅក្មេងៗសប្បាយអត់?សប្បាយតើយាយណោះ?យាយគិតថាអើរ...ជំនាន់អីគេដែរយាយពិបាកជាងគេ?

ខ៖ ខ្ញុំដឹងតែជំនាន់ខ្ញុំ។

ក៖ ជំនាន់អីគេពិបាកជាងគេយាយ?

ខ៖ ដឹងតែជំនាន់ថា មិនមែនរាជាអាពត ចូលឆ្នាំមួយៗសប្បាយណាស់ចូលឆ្នាំ ចេះតែរាំចេះតែទៅមើលគេទៅណាស់។

ក៖ ចាស!

ខ៖ មានតែប៉ុណ្ណឹងទេខ្ញុំ បានតែមើលគេទេ អត់បានចេះរាំចេះអីគេទេ។

ក៖ ចុះយាយមានចេះឧបករណ៍ភ្លេងខ្មែរអីអត់?

ខ៖ អត់ទេ។

ក៖ អត់ទេ?ចុះចូលចិត្តចម្រៀងដែរឬក៏អត់យាយ?

ខ៖ ហាំ?

ក៖ ចូលចិត្តចម្រៀងឬក៏អត់?

ខ៖ ចូលចិត្តដែរ។

ក៖ ចាសចុះយាយចេះច្រៀងឬក៏អត់យាយ?

ខ៖ អត់។

ក៖ អត់ចេះច្រៀងទេ?ចុះយាយចង់ច្រៀងអត់?

ខ៖ អត់ចង់ទេ។

ក៖ អត់ចង់ទេ?

ខ៖ ចង់អីចាស់ហើយ កាលពេលនៅក្មេងដែរចង់ដែរ។

ក៖ ចាសយាយចូលចិត្តបទចម្រៀងរបស់អ្នកណាគេយាយ?

គ៖ កាលពីក្មេង?

ក៖ កាលពេលក្មេងណាស់?

ខ៖ បទចម្រៀង?

ក៖ របស់អ្នកណាគេយាយ?

គ៖ ស៊ិន ស៊ីសាមុត?

ខ៖ បទ...?

ក៖ បទស៊ីន ស៊ីសាមុត ឬក៏រស់ សេរីសុទ្ធាអី?

ខ៖ អត់ទេ យើងចេះតែពីក្មេងមកយើងចេះតែលេងយីកេលេងអីទៅយើងចូលចិត្តហើយ។

ក៖ ចាស!

ខ៖ គេលេងយីកេគេលេងល្ខោនអីទៅមើលហើយ ដល់ភ្លឺអីនោះ។

កៈ ហ៊ុំ... ល្ខោនពេលមុនលេងដល់ភ្លឺតែម្តងយាយ?

ខៈ ចូលចិត្តចូលចិត្តដែរ ល្បែង ខ្ញុំចូលចិត្តតែមើលគេទេ។

កៈ ចាសតែអត់ចូលចិត្តលេងខ្លួនឯងទេ។

ខៈ អត់ទេ។

កៈ យាយធ្លាប់ទៅនៅខេត្តណាខ្លះទៅយាយ?

ខៈ អីគេ?

កៈ ធ្លាប់ទៅនៅខេត្តណាខ្លះទៅ?ដូចថាខេត្តផ្សេងៗយាយធ្លាប់ទៅនៅអត់?

ខៈ ម៉េចសួរម៉េចទេ?

កៈ យាយធ្លាប់ទៅនៅខេត្តផ្សេងអត់?

គៈ ខេត្តផ្សេងៗទៀតម៉ែឯងដែលធ្លាប់ទៅនៅទេ?

កៈ ដូចជា កំពង់ចាម ដូចជាខេត្តកណ្តាល កំពង់ឆ្នាំងអីយាយដែរទៅនៅអត់?

ខៈ មិនដែលទៅហោ?

កៈ មិនដែលទៅនៅហោ?

ខៈ អត់ទេ អត់ដែលទៅនៅទេ។

កៈ ចាសធ្លាប់តែទៅនៅតែខេត្តតាកែវនេះមួយទេ។

ខៈ ចាសអត់។

កៈ ហើយកាលពេលជំនាន់ប៉ុល ពតនៅបាត់ដំបង?

ខៈ ចាសហួសទៅបាត់ដំបង។

ក៖  ចាសហើយចុះប្ដីរបស់លោកយាយហ្នឹងគាត់ដូចថាគាត់ធ្លាប់ធ្វើការងារអីផ្សេងក្រៅពីធ្វើស្ករធ្វើត្នោតអីហ្នឹងដែរអត់?មានធ្វើដូចជាទាហាន?

ខ៖ ធ្វើ....។

ក៖ ហ្អំ....ធ្លាប់ធ្វើទាហានដែរ?

ខ៖ ធ្វើទាហាន។

ក៖ ចាស!

ខ៖ ទៅស្រុកគេគាត់ឈប់ធ្វើត្នោតដល់ពេលគាត់ចាស់ទៅគាត់ធ្វើទាហាន។

ក៖ ចាសគេឱ្យគាត់ទៅឬក៏គាត់ចង់ទៅលោកយាយ?

ខ៖ គេសួរយើងដែរ គេហៅយើងទៅយើងចូលចិត្តចង់ធ្វើយើងធ្វើទៅ។

ក៖ ចាស!

ខ៖ ព្រោះយើងធ្វើក៏បានមិនធ្វើក៏បាន។

ក៖ តាមចិត្តយើងដែរ បើអ្នកខ្លះគេត្រូវចុចឈ្មោះយកទៅតែម្ដង។

ខ៖ ចាសតាមចិត្តយើង។

ក៖ ចាសគាត់ទៅធ្វើទាហានដល់ណាទៅយាយ?

ខ៖ គាត់ធ្វើដែរ។

ក៖ គាត់ធ្វើដល់ណាទៅ?

ខ៖ គាត់ធ្វើទៅអញ្ចឹង ទៅយើងបាត់ដំបងទៅអីអញ្ចឹងទៅណាស់។

ក៖ ចាសគាត់អត់ដែលចាញ់អីណាយាយណោះ ចាញ់ទឹកចាញ់ដី ហាំ?

ខ៖ អត់ទេ។

កៈ ខ្ញុំធ្លាប់លឺអ្នកខ្លះ និយាយទៅបាត់ដំបងទៅប៉ៃលិនអីចាញ់ទឹកចាញ់ដីអញ្ចឹងណាស់។

ខៈ គាត់អត់ដែលចាញ់ទេ។

កៈ
ចាសចុះលោកយាយតាំងពីពេលលរៀបការជាមួយតាតាំងតែពីពេលអាយុប៉ុន្មានដែរលោកយាយ?

ខៈ ការតាំងតែពីពេលអាយុ១៨ណោះខ្ញុំ។

កៈ ចាស១៨។

ខៈ តែគាត់ខ្ទង់៣០ គាត់បងខ្ញុំច្រើនណាស់។

គៈ ហាំ...ខ្ទង់៣០ម្លេះ ម៉ែឯង១៨គាត់៣០បងពីរជួរម្លេះ និយាយខុសហើយ។

ខៈ តាមាសគាត់អាយុច្រើនជាងអញ។

កៈ តាគាត់អាយុច្រើន តាគាត់អាយុច្រើនជាងយាយ យាយ១៨តា៣០ជាងពេលការហ្នឹង។

គៈ មិនមែនទេ២០ជាងគាត់។

កៈ ២០ជាងទេណោះមិនមែន៣០ជាងទេ យាយប្រហែលជាច្រឡំហើយមើលទៅ។

គៈ គាត់ធ្លាប់និយាយប្រាប់ខ្ញុំថាពុកហ្នឹងបងគាត់១២ឆ្នាំ។

កៈ ចាស!

ខៈ គាត់និយាយថាពុក៣០ជាងហើយគាត់១៨ហ្នឹងខុសច្រើនពេកណាស់។

កៈ ចាសប្រហែលជាគាត់ភ្លេចច្រើនអញ្ចឹងណាស់ ចុះលោកយាយលោកតាគាត់ធ្លាប់នេះអត់ធ្វើផ្ទះធ្វើអីខ្លួនឯងអត់តា?តាហាំ...គាត់ធ្លាប់ធ្វើផ្ទះខ្លួនឯងអត់យាយ?

គៈ ចេះធ្វើជាងធ្វើអីខ្លួនឯង។

កៈ យាយតាធ្លាប់ធ្វើផ្ទះខ្លួនឯងអត់?គាត់ចេះធ្វើផ្ទះអត់?

ខ៖ គាត់អត់ធ្វើផ្ទះនៅហេ?

ក៖ ចាស!

ខ៖ ផ្ទះធ្វើខ្លួនឯង។

ក៖ គាត់ចេះធ្វើខ្លួនឯងដែរ?

ខ៖ ចាស!

ក៖ ចាសមិនមែនជួលជាងទេ?ខ្លះទាល់តែគាត់ជួលជាងបានគាត់នេះ...ចុះលោកយាយតាំងពីតូចមកលោកយាយមានផលលំបាកអីគេខ្លាំងជាងគេ?តាំងពីតូចមកហាំ?

គ៖ គាត់មិនសូវពិបាកទេ។

ខ៖ អ្នកណាគេ??

ក៖ យាយកាលពេលពីតូចមកធ្លាប់មានផលលំបាកអីគេខ្លាំងជាងគេ?នៅពេលណា?

គ៖ និយាយពីប្រវត្តិម៉ែឯងនៅជាមួយម្ដាយពិបាកដែរអត់ដូចជាដើរលក់ដូរហាត់នឿយស្អីអញ្ចឹងទៅណាស់ គាត់អត់ពិបាកទេមីអូនអើយគាត់កើតមកចំកូនចៅគាត់អ្នកមានគាត់អត់ពិបាក។

ក៖ ហ្ហ៎...កើតមកចំកូនអ្នកមាន?

គ៖ ហើយគាត់អត់មានពិបាកអីគេទេប្រវត្តិគាត់នោះ។

ក៖ អញ្ចឹងយាយគាត់អត់មានពិបាកអត់មានអីទេ។

គ៖ នៅក្នុងបន្ទុកម្ដាយគាត់អត់ពិបាកអីគេទេ។

ក៖ ចាសជីវភាពគ្រាន់បើដែរ។

គ៖ គាត់អត់ពិបាកទេម៉ែគាត់មាន។

កៈ ហ្ហ៎...ម្តាយលោកយាយមាន?

គៈ ជីតារបស់គាត់ក៏មានដែរ។

កៈ ចាស!

គៈ គាត់អត់មានពិបាកជីវភាពអីខ្វះខាត អត់ហូបអត់អីទេ។

កៈ ចាស!

គៈ គាត់ទើបតែពិបាកទើបតែប៉ុល ពត ហើយនឹងមានប្តីអីហ្នឹងទេ។

កៈ ចាស!

គៈ គាត់នៅក្មេងជាមួយម្តាយគាត់នៅចំម៉ែឪមានហូបមានចុកធូរធារ។

កៈ ចាស!

គៈ គាត់និយាយ។

កៈ អញ្ចឹងកាលពេលគាត់នៅក្មេងគាត់ស្រណុក គ្រាន់តែពិបាកនៅក្នុងពេលជំនាន់ប៉ុល ពតហើយចាប់តាំងពីមានគ្រួសារខ្លួនឯងអាហ្នឹងបានគាត់ពិបាក?

គៈ ហ្នឹងហើយ។

កៈ ចុះលោកយាយកាលពេលនៅតូចលោកយាយសង្ឃឹមចង់ធ្វើការងារអីមួយអត់?ឥឡូវដូចថាស្រលាញ់ការងារអីគេយាយ?

ខៈ ខ្ញុំហេ?

កៈ ចាស!

ខៈ អត់មានស្រលាញ់អីទេ អត់មានចិត្តទៅលើអី។

កៈ អត់ចង់ធ្លាប់មានបំណងប្រាថ្នាធ្វើអីមួយអញ្ចឹងណាស់?

ខៈ អត់ ដូចថាវាអត់ចេះអក្សរអត់ចេះអានអត់ចង់ធ្វើ។

ក៖
ចាសចុះលោកយាយដូចថាមានទុក្ខលំបាកអីគេទៀតដែលកើតឡើងចំពោះលោកយាយពេលបច្ចុប្បន្នអញ្ចឹងណាស់ មានធ្លាប់មានបញ្ហាអីគេខ្លះទៀតទេយាយ?

ខ៖ អត់ទេ អត់មានបញ្ហាអីគេទៀតទេអត់។

ក៖ ចាសរាល់ថ្ងៃរស់នៅសុខសាន្តធម្មតា?

ខ៖ ធម្មតាធ្វើការងារដល់ខែដកៗទៅ ស្ទូងៗទៅ។

គ៖ ធ្វើស្អីគេបើយាយឯងនៅលើគ្រែ២០ឆ្នាំជាងហើយ មិនព្រមថាអត់មានធ្វើអីគេទេ នៅតែលើគ្រែអញ្ចេះទៅអត់។

ក៖ លោកយាយគាត់នៅលើគ្រែអញ្ចឹង២០ឆ្នាំជាងហើយ?

គ៖ ចាសហើយថាដល់ខែដកស្ទូងទៅធ្វើទៅ ធ្វើស្អីគេឱ្យតែគេបម្រើនិយាយអត់មានពិចារណាអីនិយាយឱ្យតែឆ្លើយឱ្យតែរួចៗតែម្តង និយាយខ្ជិលឆ្លើយ។

ក៖
ចុះលោកយាយធ្លាប់ទាន់សម័យសម្តេចតាតើលោកយាយមានហេតុការអីគេខ្លះកើតឡើងលោកយាយ?ការពេលជំនាន់សម្តេចតាទួតណាស់
សម្តេចសីហនុណាស់?តើយាយបានជួបអីគេខ្លះឬក៏ហេតុការអីគេខ្លះ
ដែលធ្លាប់បានឃើញផ្ទាល់ភ្នែកអត់យាយ?

ខ៖ អត់ អត់មានឃើញអីទេគ្រាន់តែដឹង...។

ក៖ យាយដឹងពីបញ្ហាអីគេទៅយាយ?

ខ៖ ខ្ញុំវានៅក្មេងដែរ។

ក៖ ចាស!

ខ៖ អាយុប៉ុន្មាន?

គ៖ អត់មានដឹងបញ្ហាដេកយប់ឡើងម៉េចៗ?

ក៖ យាយអត់មានបានឃើញគ្រាប់បែកគ្រាប់ផ្លោងអីផ្ទាល់ភ្នែកអី?

គ៖ គ្រាប់បែកគ្រាប់ផ្លោង ម៉ែឯងនៅបឹងជំពន់នោះ រត់យប់អាធ្រាត្រ វ៉ូវ៉ូ...មកនាំគ្នាចូលក្នុងរណ្ដៅត្រង់សេហ្នុ៎...។

ខ៖ មាន។

គ៖ អត់និយាយ។

ខ៖ មានគ្រាប់មក។

គ៖ មិនមែនថាម៉ែឯងភ្លេចសោះទេ ម៉ែដល់តែសួរទៅដូចជាយ៉ាងម៉េចទេ។

ខ៖ គេផ្លោងដាក់មក។

ក៖ ដូចថាយាយគាត់រកនឹកអត់ទាន់ឃើញអញ្ចឹងទៅណាស់។

ខ៖ ចេះតែអញ្ចឹងទៅគិតភ័យខ្លាច គ្រាប់មករត់ទៅដេកវត្តឯណោះ រត់អីអញ្ចឹងទៅ។

គ៖ អាថារិទ្ធអី កាលពេលចំបក់ហ្នឹងនៅតូចៗអីរត់ចូលរណ្ដៅត្រង់សេហ្នឹង។

ក៖ ចាសចុះលោកយាយអើរ...មានអីចង់ផ្ដាំផ្ញើទៅកាន់កូនចៅយាយជំនាន់ក្រោយអត់យាយចង់មានពាក្យអីនិយាយអញ្ចឹងណាស់?

ខ៖ ចាស!

ក៖ ផ្ដាំផ្ញើរអីគេខ្លះយាយ?

ខ៖ អត់ អត់ទេ អត់មានអី។

ក៖ ដូចថាឱ្យខំប្រឹងធ្វើអីមួយឬក៏ជៀសផុតពីបញ្ហាគ្រឿងញៀន ឬក៏អោយធ្វើអំពើសុចរិត

អីអញ្ចឹងណាស់?

ខ៖ អើរ...!

កៈ យាយចង់ផ្ដាំអីគេទៅយាយ?

គៈ
ផ្ដាំកុំឱ្យភ្លើតភ្លើនអីអញ្ចឹងទៅម៉ែឯងនិយាយអត់កើតទេហោ?ម៉ែឯងអត់ចេះណែនាំកូនចៅទេហោសគ្រាន់តែនិយាយប៉ុណ្ណឹងហ្នឹង គ្រាន់តែថាខ្ញុំចង់ឱ្យកូនចៅខ្ញុំជំនាន់ក្រោយកុំឱ្យមាន...។

កៈ ជួបបញ្ហាគ្រឿងញៀន?

គៈ ជួបបញ្ហាគ្រឿងញៀន ដូចជាដើរលេង ប្លន់គេឬក៏អីអញ្ចឹងទៅ និយាយអត់កើតយាយ

អើយ...យាយ។

កៈ
លោកយាយដល់ពេលគាត់រៀងវង្វេងទៅគាត់រៀងស្ដាប់មិនសូវបានអញ្ចឹងណាស់មានតែការផ្ដាំផ្ញើអោយកូនចៅជំនាន់ក្រោយសុខសប្បាយហើយខំប្រឹងរៀនសូត្រហើយកុំប្រព្រឹត្តគ្រឿងញៀនអីអញ្ចឹង។

គៈ ធ្វើតែអំពើល្អអីអញ្ចឹងទៅ។

កៈ ចាសធ្វើអំពើល្អ
អញ្ចឹងខ្ញុំសូមអរគុណលោកយាយព្រោះអីរំខានយាយនិយាយយូរពេកហើយព្រោះអីលោកយាយចាស់ហើយ។

ខៈ ចាស់ហើយ។

កៈ ហើយគាត់ពិការភ្នែកទៀតហើយគាត់វង្វេងច្រើនហើយលោកយាយអត់សូវបាននិយាយអីដូចថានិយាយច្រើនហើយ។

ខៈ រម៉ាស់ភ្នែកផង។

កៈ ចាសដោយសារមានបញ្ហាភ្នែកផង បញ្ហាត្រចៀកផងច្រើនមុខផង អញ្ចឹងខ្ញុំសូមអរគុណលោកយាយដែលបានឱ្យខ្ញុំសម្ភាសនៅក្នុងថ្ងៃនេះហើយការសម្ភាសនេះត្រូវបានដាក់បញ្ចូលនៅក្នុងសកលវិទ្យាល័យ ប៊ី វ៉ាយ យូ សហរដ្ឋអាមេរិចហើយអើរ...គេបានដាក់បញ្ចូលនៅក្នុងវេបសាយរបស់សាលាហ្នឹងហើយអើរ...លោកយាយអា

ចឱ្យកូនចៅជំនាន់ក្រោយអាចស្តាប់ពីសម្លេងឃើញពីរូបភាពរបស់យាយអញ្ចឹងបាន
ដើម្បីរក្សាទុកឱ្យលោកយាយ អញ្ចឹងខ្ញុំសូមអរគុណលោកយាយ សូមជំរាបលាលោកយាយ៕